**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៣៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំជាថ្មីនូវគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២០អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៣

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១**: អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

## ជំពូកទី ២
## តួនាទី និងភារកិច្ច

**មាត្រា ២**: គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានប្រធានដឹកនាំរួម និងមានអនុប្រធាន ព្រមទាំងសមាជិកជាជំនួយការរបស់ប្រធាន ហើយត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។

**មាត្រា ៣**: គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដែលមានអក្សរកាត់ គ.ស.ម.ក មានភារកិច្ច ៖

- ការពារ លើកស្ទួយ អភិវឌ្ឍសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ត្រួតពិនិត្យរាល់ការរំលោភសិទ្ធិមនុស្សនិងពាក្យបណ្ដឹងតវ៉ានានា
- ស្រាវជ្រាវអង្កេតករណីនានា ឬធ្វើការវាយតម្លៃការស្រាវជ្រាវអង្កេតរបស់សមត្ថកិច្ច ឬសហការស្រាវជ្រាវអង្កេតជាមួយសមត្ថកិច្ច ហើយធ្វើសំណុំឯកសារ ផ្សព្វផ្សាយ ជូនសាធារណៈជន ជូននាយករដ្ឋមន្ត្រី ជូនតុលាការ និងជូនសមត្ថកិច្ចនោះវិញ
- ចុះត្រួតពិនិត្យតាមមូលដ្ឋាននានា ដើម្បីធ្វើការវាយតម្លៃនិងផ្ដល់ឱវាទអំពីសិទ្ធិមនុស្ស
- អប់រំផ្សព្វផ្សាយអំពីសិទ្ធិមនុស្សជាសាធារណៈនិងតាមមុខសញ្ញានីមួយៗ
- កសាងភ្នាក់ងារ និងមន្ត្រីឃ្លាំមើលសិទ្ធិមនុស្សស្ម័គ្រចិត្តរបស់ខ្លួននៅតាមស្ថាប័នរដ្ឋ ឯកជន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ
- ផ្ដល់យោបល់និងលើកសំណើជូនរាជរដ្ឋាភិបាលអំពីសភាពការណ៍សិទ្ធិមនុស្ស សំដៅធ្វើការកែលំអនិងធ្វើយ៉ាងណាឲ្យស្របនឹងរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិ
- លើកមតិនិងចូលរួមមតិក្នុងការកែទម្រង់ទាំងឡាយរបស់រាជរដ្ឋាភិបាល
- ចូលរួមកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនិងចូលរួមផ្ដល់យោបល់លើសេចក្ដីព្រាងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ដែលពាក់ព័ន្ធនឹងវិស័យសិទ្ធិមនុស្ស
- សហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនិងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលជាស្ថាប័នទទួលខុសត្រូវលើសិទ្ធិកុមារនិងសិទ្ធិនារី និងស្ថាប័នសិទ្ធិមនុស្សនានារបស់រដ្ឋដើម្បីជម្រុញការអភិវឌ្ឍសិទ្ធិមនុស្សតាមផ្នែកនិមួយៗឲ្យបានល្អ
- ជួយដល់រាជរដ្ឋាភិបាលជំរុញការងារនីតិរដ្ឋនិងការបណ្ដុះបណ្ដាលអ្នកច្បាប់ទាក់ទងនឹងបញ្ហាសិទ្ធិមនុស្ស
- ក្នុងនាមរាជរដ្ឋាភិបាលផ្ដល់សេវាប្រឹក្សាច្បាប់និងផ្ដល់មេធាវីជួយការពារក្ដីដល់ជនក្រីក្រឬអ្នកដែលត្រូវមេធាវីទាំងឡាយបដិសេធមិនព្រមទទួលការពារក្ដី
- គាំទ្រ សហការជាមួយក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិល ដើម្បីបុព្វហេតុការពារ និង

អភិវឌ្ឍវិស័យសិទ្ធិមនុស្សនៅកម្ពុជា

- រៀបចំរបាយការណ៍ជាតិជូនរាជរដ្ឋាភិបាលស្តីពីការអនុវត្តលិខិតបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធទៅនឹងវិស័យសិទ្ធិមនុស្ស និងរបាយការណ៍បំភ្លឺនានាសម្រាប់សាធារណមតិជាតិនិងអន្តរជាតិ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា ៤**: គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ប្រជុំរាល់ ០៦ខែម្តង តាមការអញ្ជើញរបស់ប្រធាន ដើម្បីត្រួតពិនិត្យវាយតម្លៃការងារ និងលើកទិសដៅការងារ ។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា រៀបចំសន្និបាតទូទាំងប្រទេស ០២ឆ្នាំម្តង ដើម្បីវាយតម្លៃស្ថានភាពសិទ្ធិមនុស្ស និងលើកសំណូមពរអភិវឌ្ឍន៍ជាបន្ត ។ របាយការណ៍របស់សន្និបាត ត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ៥**: ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ធ្វើការតំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជាក្នុងវិស័យការងារសិទ្ធិមនុស្សកម្ពុជា ។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**មាត្រា ៦**: គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មាន២ អគ្គនាយកដ្ឋាន ៖

១- អគ្គនាយកដ្ឋានរដ្ឋបាល និងពាក្យបណ្តឹង : ទទួលការងារ រដ្ឋបាល ហិរញ្ញវត្ថុ គ្រប់គ្រង និងសេវានានា បំរើឱ្យគណៈកម្មាធិការ ទំនាក់ទំនងសាធារណៈ ទំនាក់ទំនងសិទ្ធិមនុស្សក្នុងប្រទេស និងក្រៅប្រទេស ពាក្យបណ្តឹងតវ៉ា រៀបចំបណ្តាញ និងបណ្តុះបណ្តាលមន្ត្រីឃ្លាំមើលសិទ្ធិមនុស្ស ពិសេសលើកទឹកចិត្តដោះស្រាយទំនាស់តាមរបៀបសម្រុះសម្រួល ។

២- អគ្គនាយកដ្ឋានស៊ើបអង្កេត និងអប់រំសិទ្ធិមនុស្ស : ទទួលការងារបច្ចេកទេសពាក់ពន្ធ័លើការស្រាវជ្រាវ ប្រមូលពត៌មាន ឯកសារ ធ្វើរបាយការណ៍ពីបទរំលោភសិទ្ធិមនុស្ស ការងារច្បាប់ និងជំនួយការច្បាប់ និងទទួលការងារធ្វើរបាយការណ៍តាមផ្នែកនីមួយៗ នៃអនុសញ្ញាអន្តរជាតិ បណ្តុះបណ្តាលអប់រំផ្សព្វផ្សាយសិទ្ធិមនុស្ស រៀបចំវេទិការសាធារណៈមតិ និងបើកលទ្ធភាពឱ្យមានការសួរដេញដោលដោយសេរី ។

**មាត្រា ៧**: មន្ត្រី បុគ្គលិកបំពេញការងារក្នុងស្ថាប័ននេះ ជាមន្ត្រីបុគ្គលិករាជការដែលមានក្របខណ្ឌស្រាប់ ឬក្របខ័ណ្ឌដែលស្ថាប័នមុខងារសារធារណៈជាអ្នកផ្ដល់មកឱ្យ ។ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា អាចទទួលបាននូវអ្នកស្ម័គ្រចិត្តមួយចំនួន ដែលពុំយកប្រាក់បៀវត្សពីរដ្ឋអោយធ្វើជាទីប្រឹក្សា និងអ្នកជំនាញ ។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា អាចស្នើតែងតាំងទីប្រឹក្សា និងអ្នកជំនាញការខ្មែរ និងបរទេសអមគណៈកម្មាធិការដើម្បីជួយសិក្សា និងផ្ដល់យោបល់ពីការងារជំនាញនីមួយៗ ។ ទីប្រឹក្សា និងអ្នកជំនាញការខ្មែរអាចមានឋានៈពីប្រធាននាយកដ្ឋានឡើងទៅ ។

## ជំពូកទី ៤
## ប្រភពធនធាន

**មាត្រា ៨**: រាជរដ្ឋាភិបាលមានភារកិច្ចផ្ដល់មធ្យោបាយការងារ ថវិកាសំរាប់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា អាចបំពេញការងាររបស់ខ្លួនបានល្អ ។ ថវិការបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាជាបន្ទុករបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៥
## អំពីរូបសញ្ញា និងត្រា

**មាត្រា ៩**: គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានរូបសញ្ញា និងត្រាផ្ទាល់របស់ខ្លួន ។

**មាត្រា ១០**: តួនាទី ភារកិច្ច រូបសញ្ញា និងត្រារបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាត្រូវកំណត់ក្នុងអនុក្រឹត្យដោយឡែក ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១១**: ព្រះរាជក្រឹត្យលេខ នស/រកត/០១០០/០០៨ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៦៣ ចុះថ្ងៃ ទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្ដីពីការកែសម្រួលមាត្រា២ និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត /០១០០/០០៨ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

- សម្របសម្រួល សហការ និងផ្តល់យោបល់លើកិច្ចការសិទ្ធិមនុស្សរបស់អង្គការសិទ្ធិមនុស្សក្នុងថ្នាក់តំបន់
- សិក្សាស្វែងយល់ពីយន្តការការពារសិទ្ធិមនុស្សរបស់រដ្ឋជាសមាជិកអាស៊ាននិងរបស់តំបន់នានា
- ធ្វើជាសេនាធិការឲ្យរាជរដ្ឋាភិបាលកម្ពុជាក្នុងស្ថាប័នសិទ្ធិមនុស្សអាស៊ាននិងតំបន់
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

នាយកដ្ឋានសិទ្ធិមនុស្សតំបន់និងអាស៊ាន ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា ៩:** រចនាសម្ព័ន្ធថ្នាក់ក្រោមនាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

## ជំពូកទី ៥
## អគ្គនាយកដ្ឋានស៊ើបអង្កេត និងអប់រំសិទ្ធិមនុស្ស

**មាត្រា ១០:** អគ្គនាយកដ្ឋានស៊ើបអង្កេតនិងអប់រំសិទ្ធិមនុស្ស ជាសេនាធិការឲ្យគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ទទួលបន្ទុកលើការងារបច្ចេកទេសពាក់ព័ន្ធនឹងការស្រាវជ្រាវ ប្រមូលព័ត៌មាននិងឯកសារ ធ្វើរបាយការណ៍ពីការរំលោភសិទ្ធិមនុស្ស ការងារច្បាប់ និងជំនួយការច្បាប់ កោសល្យវិច័យ ជំនាញនានា និងទទួលតាមផ្នែកនីមួយៗនៃអនុសញ្ញាអន្តរជាតិ បណ្តុះបណ្តាល អប់រំផ្សព្វផ្សាយ សិទ្ធិមនុស្ស ដោយរៀបចំជាវេទិកាសាធារណៈ។

អគ្គនាយកដ្ឋានស៊ើបអង្កេតនិងអប់រំសិទ្ធិមនុស្ស មាននាយកដ្ឋានដូចតទៅ៖

- នាយកដ្ឋានស៊ើបអង្កេត
- នាយកដ្ឋានអប់រំសិទ្ធិមនុស្ស
- នាយកដ្ឋានសិទ្ធិមនុស្សអន្តរជាតិនិងអង្គការសហប្រជាជាតិ។

អគ្គនាយកដ្ឋានស៊ើបអង្កេតនិងអប់រំសិទ្ធិមនុស្ស ដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងមួយចំនួន តាមការចាំបាច់។

**មាត្រា ១១:** នាយកដ្ឋានស៊ើបអង្កេត មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ស៊ើបអង្កេត ត្រួតពិនិត្យ ស្រាវជ្រាវការរំលោភសិទ្ធិមនុស្សដោយខ្លួនឯង ឬដោយសហការស៊ើបអង្កេតជាមួយអាជ្ញាធរមានសមត្ថកិច្ច និងអង្គការសង្គមស៊ីវិល លើករណីរំលោភសិទ្ធិមនុស្ស
- ត្រួតពិនិត្យវិស័យសិទ្ធិមនុស្សនៅតាមពន្ធនាគារ មណ្ឌលអប់រំកែប្រែ កន្លែងឃុំឃាំង និងមណ្ឌលស្តារនីតិសម្បទា

- ស្រាវជ្រាវប្រមូលព័ត៌មាន និងភស្តុតាងពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សក្នុងគ្រប់រូបភាព
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធដើម្បីការពារសន្តិសុខនិងសុវត្ថិភាពជូនសាក្សីនិងជនរងគ្រោះ
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ អំពីសកម្មភាពការងាររបស់នាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

នាយកដ្ឋានស៊ើបអង្កេត ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា ១២**: នាយកដ្ឋានអប់រំសិទ្ធិមនុស្ស មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំកសាងផែនការយុទ្ធសាស្ត្រ និងនយោបាយស្តីពីកម្មវិធីសិក្សានិងវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្ស
- អប់រំ ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្សដល់អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ សិស្ស និស្សិត កម្មករ ប្រជាពលរដ្ឋ និងក្រុមជនជាតិភាគតិច
- សហការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបញ្ចូលកម្មវិធីអប់រំ ដើម្បីយល់ដឹងអំពីសិទ្ធិមនុស្ស
- រៀបចំសិក្ខាសាលានិងរៀបចំវេទិកាសាធារណៈ
- រៀបចំនិងគ្រប់គ្រងកិច្ចការបណ្ណាល័យ បណ្ណសារ សម្រាប់សិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងវិស័យសិទ្ធិមនុស្ស
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ អំពីសកម្មភាពការងាររបស់នាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

នាយកដ្ឋានអប់រំសិទ្ធិមនុស្ស ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា ១៣**: នាយកដ្ឋានសិទ្ធិមនុស្សអន្តរជាតិនិងអង្គការសហប្រជាជាតិ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ពិនិត្យព័ត៌មានដែលមានស្រាប់និងស្រាវជ្រាវព័ត៌មានបន្ថែមដូចជាច្បាប់ គោលនយោបាយ សារាចរណែនាំ សេចក្តីសម្រេច ការអនុវត្ត និងស្ថានភាពជាក់ស្តែងដែលពាក់ព័ន្ធទៅនឹងកតិកាសញ្ញា អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិ
- រៀបចំសរសេររបាយការណ៍ស្តីពីការអនុវត្តលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ ពាក់ព័ន្ធនឹងវិស័យសិទ្ធិមនុស្ស
- រៀបចំសរសេររបាយការណ៍ជាតិតាមកាលកំណត់

- សម្របសម្រួល សហការ និងផ្តល់យោបល់ លើកិច្ចការសិទ្ធិមនុស្ស ជាមួយអង្គការសហប្រជាជាតិនិងអង្គភាពសិទ្ធិមនុស្សនានា
- សម្របសម្រួល និងសហការជាមួយនាយកដ្ឋានតាមបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីស្វែងរកទិន្នន័យថ្មីៗពាក់ព័ន្ធនឹងកតិកាសញ្ញា អនុសញ្ញា និងអនុសាសន៍នានារបស់អង្គការសហប្រជាជាតិបញ្ចូលទៅក្នុងរបាយការណ៍ជាតិ
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ អំពីសកម្មភាពការងាររបស់នាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

នាយកដ្ឋានសិទ្ធិមនុស្សអន្តរជាតិនិងអង្គការសហប្រជាជាតិ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា ១៤**: រចនាសម្ព័ន្ធថ្នាក់ក្រោមនាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

## ជំពូកទី ៦
## មន្ត្រីឃ្លាំមើលសិទ្ធិមនុស្សស្ម័គ្រចិត្ត

**មាត្រា ១៥**: នៅតាមបណ្តារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានមន្ត្រីឃ្លាំមើលសិទ្ធិមនុស្សស្ម័គ្រចិត្ត ដែលមានភារកិច្ចសម្របសម្រួល និងឃ្លាំមើលការអនុវត្តការងារសិទ្ធិមនុស្សនៅមូលដ្ឋាន តាមការណែនាំរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

**មាត្រា ១៦**: មន្ត្រីឃ្លាំមើលសិទ្ធិមនុស្សស្ម័គ្រចិត្តត្រូវតែងតាំងដោយប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ។

## ជំពូកទី ៧
## រូបសញ្ញា និងត្រាគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

**មាត្រា ១៧**: រូបសញ្ញាគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានរូបភាពដូចតទៅ៖

- រូបភូគោលពណ៌ទឹកសមុទ្រលាយពណ៌ស្វាយដែលមានទំរពណ៌ត្នោត តំណាងឲ្យទឹកដីជីវិត មនុស្ស សត្វ និងវត្ថុទាំងអស់ដែលមានអត្ថិភាពនៅក្នុងពិភពលោក
- រូបផែនទីប្រទេសកម្ពុជាពណ៌បៃតងខ្ចី នៅលើភូគោលតំណាងឲ្យប្រទេសកម្ពុជា មានឯករាជ្យនិងសេរីភាពពេញលេញក្នុងក្របខ័ណ្ឌពិភពលោក ដែលមានសិទ្ធិស្មើគ្នាលើឆាកអន្តរជាតិ ហើយនេះក៏ជានិមិត្តរូបនៃភាពស្មើគ្នារបស់មនុស្សផងដែរ
- រូបកួរស្រូវពណ៌មាស៧៩គ្រាប់ ទ្រភូគោលផ្នែកខាងឆ្វេង តំណាងឲ្យភាពសម្បូរសប្បាយ ភាពរីកលូតលាស់លើគ្រប់វិស័យ ភាពសុខដុមរមនា និងសុភមង្គលគ្រប់បែបយ៉ាង ដែលឆ្លុះបញ្ចាំងនូវភាពរីកចម្រើនឥតឈប់ឈរ ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩
- រូបធាងស្លឹកអូលីវពណ៌បៃតង ៧ទង ទ្រភូគោលផ្នែកខាងស្តាំ តំណាងឲ្យការចង់បានសុខសន្តិភាពជាមួយប្រទេសនានាទាំងអស់ ក្នុងពិភពលោកដែលស្រលាញ់លទ្ធិប្រជាធិបតេយ្យ។ ធាងស្លឹកអូលីវនេះក៏តំណាងផងដែរនូវសេចក្តីយុត្តិធម៌ លើកស្ទួយសិទ្ធិរស់នៅរបស់ប្រជាជនទូទៅ ដោយគ្មានការរើសអើងពណ៌សម្បុរនិងជាតិសាសន៍

ឡើយ ពោលគឺលើកស្ទួយវិស័យសិទ្ធិមនុស្សទូទៅ។ ស្លឹកអូលីវ៧ទង ចង់រំលឹកពីថ្ងៃ ៧មករា ជាថ្ងៃដែលប្រជាជនកម្ពុជាទទួលបានសិទ្ធិរស់រានមានជីវិតមកវិញ។ រូបសញ្ញាដែលមានខ្លឹមសារដូចបានចែងខាងលើជាឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

**មាត្រា ១៨**: រូបសញ្ញារបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ត្រូវបានប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- ដាក់នៅលើក្បាលលិខិតផ្លូវការរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- ប្រើក្នុងករណីផ្សេងៗទៀតដោយមានការឯកភាពពីគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

**មាត្រា ១៩**: គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានត្រាមូលប្រើសម្រាប់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

ត្រារបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានវណ្ណពីរជាន់ រំលេចរូបប្រាសាទអង្គរវត្តកំពូលបីនៅចំកណ្តាល។ ផ្នែកខាងលើរូបប្រាសាទអង្គរវត្តកំពូលបី មានឆ្លាក់អក្សរ "ព្រះរាជាណាចក្រកម្ពុជា" ស្របតាមវណ្ណ ផ្នែកខាងក្រោមមានឆ្លាក់អក្សរ "គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា" ស្របតាម វណ្ណ និងនៅចន្លោះរូបទាំងពីរមានរូបផ្កាចន្ទន៍នៅសងខាង។ ត្រាដែលមានខ្លឹមសារដូចបានចែងខាងលើ ជាឧបសម្ព័ន្ធ៣នៃអនុក្រឹត្យនេះ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ២០**: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២១**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី(១៧)ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ